ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ✓

# សេចក្តីអំពាវនាវ

លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ត្រូវបានអនុវត្តយ៉ាងសកម្មទទួលបានលទ្ធផលគួរឲ្យកត់សម្គាល់ អាស្រ័យដោយមានការគាំទ្រនិងចូលរួមយ៉ាងសស្រាក់សស្រាំពីសំណាក់ប្រជាពលរដ្ឋ និងគ្រប់សមាសភាពក្នុងសង្គម។ លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការចូលរួមដ៏ថ្លៃថ្លានេះ ប៉ុន្តែនៅកត់សម្គាល់ឃើញថា នៅមានម្ចាស់ទីតាំងមួយចំនួនដូចជា សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះជួល ក្លឹបកំសាន្ត ខារ៉ាអូខេ ឌីស្កូ ដែលជាគោលដៅងាយរងគ្រោះដោយបទល្មើសគ្រឿងញៀន មិនទាន់មានស្មារតីប្រុងប្រយ័ត្ន និងមានកិច្ចសហការល្អជាមួយសមត្ថកិច្ចនៅឡើយ។

លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សូមអំពាវនាវដល់ម្ចាស់ទីតាំងអាជីវកម្មទាំងអស់ត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងដើម្បីបង្ការកុំឲ្យកើតមានបទល្មើសគ្រឿងញៀននៅក្នុងទីតាំងរបស់ខ្លួន និងសូមមេត្តាចូលរួមផ្តល់កិច្ចសហការល្អប្រសើរជាមួយសមត្ថកិច្ច។

លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សូមបញ្ជាក់ថា ក្នុងករណីបណ្តែតបណ្តោយឲ្យកើតមានបទល្មើសគ្រឿងញៀនក្នុងទីតាំងរបស់ខ្លួន ម្ចាស់ទីតាំងនឹងប្រឈមចំពោះការអនុវត្តច្បាប់ស្តីពី «ការត្រួតពិនិត្យគ្រឿងញៀន» ដូចមានបញ្ជាក់ជូនខាងក្រោម៖

**១. មាត្រា ៤០** : បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន
«ផ្តន្ទាទោសដាក់ពន្ធនាគារពី០២(ពីរ)ឆ្នាំ ទៅ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល»

**២. មាត្រា ៤២** : បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន
«ផ្តន្ទាទោសដាក់ពន្ធនាគារពី០២(ពីរ)ឆ្នាំ ទៅ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល»

**៣. មាត្រា ៤៣** : បទបង្ខំ អូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន
(ស្ថានទម្ងន់) «ផ្តន្ទាទោសដាក់ពន្ធនាគារពី ០៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ និងពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល»
(ស្ថានទម្ងន់) «ផ្តន្ទាទោសដាក់ពន្ធនាគារពី ១០(ដប់)ឆ្នាំ ទៅ ២០(ម្ភៃ)ឆ្នាំ និងពិន័យជាប្រាក់ពី ២០.០០០.០០០(ម្ភៃលាន)រៀល ទៅ ៤០.០០០.០០០(សែសិបលាន)រៀល»

**៤. មាត្រា ៤៤** : បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន
«ផ្តន្ទាទោសដាក់ពន្ធនាគារពី០១(មួយ)ឆ្នាំ ទៅ ០៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ១០.០០០.០០០ (ដប់លាន)រៀល»
(ស្ថានទម្ងន់) «ផ្តន្ទាទោសដាក់ពន្ធនាគារពី ០៥(ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ និងពិន័យជាប្រាក់ពី ១០.០០០.០០០(ដប់លាន)រៀល ទៅ ២០.០០០.០០០(ម្ភៃលាន)រៀល»

លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ សង្ឃឹមយ៉ាងមុតមាំ និងជឿជាក់លើស្មារតីចូលរួមរបស់ម្ចាស់ទីតាំងអាជីវកម្មទាំងអស់ ដើម្បីរួមចំណែកបំបាត់បទល្មើសគ្រឿងញៀន និងរួមគ្នារក្សាសុខសន្តិភាព សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមនៃមាតុភូមិកម្ពុជាដ៏បវរនៃយើង។

*សូមគោរពជូនពរ សុខភាពល្អ និងសុភមង្គលគ្រប់ប្រការ។*

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែតុលា ឆ្នាំ ២០១៧

**លេខាធិការដ្ឋាននៃយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់**